# ឃ្លាំមើលសកម្មភាពសភាតំណាងរាស្ត្រ សំរាប់ ខែមេសា ឆ្នាំ២០០៥

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥

ក្នុងខែមេសា ២០០៥ នេះ រដ្ឋសភាបានបើក**សម័យប្រជុំពេញអង្គចំនួនតែពីរលើក**(ព្រឹក)ប៉ុណ្ណោះ ដោយបាន**អនុម័តច្បាប់ចំនួនមួយ** គឺច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ (លើកទីពីរ ប្រជុំបានតែកន្លះពេល) ដោយសារមូលហេតុខ្វះកូរ៉ុមម្យ៉ាងដោយខែនេះជាខែដែលត្រូវប្រារព្ធពិធីចូលឆ្នាំខ្មែរផង និងរដ្ឋសភារៀបចំប្រជុំសភាអាស៊ីលើកទី២១ (ថ្ងៃទី ២៩-៣០ មេសា)ផង។ សមាជិកសភាគណបក្សសមរង្ស៊ី ដែលនៅតែបន្តធ្វើពហិកាមិនចូលប្រជុំសភា (សូមមើលលំអិតនៅចំនុចលេខ១ស្តីពីការសង្កេតមើលកិច្ចប្រជុំសភាពេញអង្គលើកទី២ នីតិកាលទី៣)។

នៅក្នុងខែនេះដែរ មាន**បញ្ហាដ៏ចំរូងចំរាស់**មួយចំនួនបានកើតឡើងផងដែរគឺដូចជា ឯកឧត្តមអគ្គលេខាធិការរដ្ឋសភា**បដិសេធក្នុងការបញ្ជូនលិខិត**របស់អ្នកតំណាងរាស្ត្រគណបក្សជំទាស់ទៅស្ថាប័នពាក់ព័ន្ធ ដែលស្នើសុំឱ្យនាយកអគ្គិសនីកម្ពុជាបំភ្លឺបញ្ហាតម្លៃភ្លើងក្នុងខេត្តកំពង់ធំដោយបានបញ្ជាក់ថា: "**អ្នកតំណាងរាស្ត្រទាំងនោះគួរបំពេញភារៈកិច្ចរបស់ខ្លួនដោយចូលរួមប្រជុំ**"។ បញ្ហានេះត្រូវបានអ្នកតំណាងរាស្ត្រដែលជាម្ចាស់លិខិតបានឆ្លើយតបវិញថា: "**ខ្លួននឹងចូលសាកសួរសំនួរ នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចចូលមកបំភ្លឺនៅក្នុងសម័យប្រជុំរដ្ឋសភា។**"

**បញ្ហាមិនប្រក្រតីមួយទៀត** គឺគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា **បដិសេធក្នុងការផ្តល់កំណត់ហេតុសម័យប្រជុំរដ្ឋសភា** ដល់មេធាវីរបស់អ្នកតំណាងរាស្ត្រសមរង្ស៊ី។ **សម្តេច ហេង សំរិន** អនុប្រធានទីមួយរដ្ឋសភាបានការពារការបដិសេធនោះថា: "*លោកមិនបានគិតថាមានតំរូវការណាមួយដើម្បីចេញកំណត់ហេតុអំពីសាធារណជន ឬក៏នរណាម្នាក់ឡើយ។ **វាជាគោលការណ៍របស់សភាជាតិ**។* [លាក់ការសំងាត់] *"*។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ ក៏មានការរិះគន់ពីសំណាក់សង្គមស៊ីវិល និងសមាជិក សភាគណបក្សប្រឆាំងផងដែរ ព្រមទាំងមានការឆ្លើយតបពីសំណាក់ថ្នាក់ដឹកនាំរដ្ឋសភាមួយចំនួន ដែលត្រូវបានដកស្រង់សំដីដោយ សារព័ត៌មាន **ឌឺ ខែមបូឌា ដេលី** ផ្សាយថ្ងៃទី២៨ មេសា ២០០៥។ លោក **គល់ បញ្ញា** នាយកប្រតិបត្តិគណៈកម្មាធិការ **ខុមហ្វ្រែល** បានមានប្រសាសន៍ថា: "*សភាជាតិបដិសេធចំពោះលំហូរនៃព័ត៌មានដោយគ្មានហេតុផលនិងគ្មានការពន្យល់។ វាមិនមែនជាការសំងាត់ជាតិទេ*"។ លោកស្រី **ជា វណ្ណាត** ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមក៏បានថ្លែងថា: "*ខ្ញុំគិតថាប្រហែលជាគ្មានរបាយការណ៍ទេ។ ឬថា ប្រហែលជាអានកំណត់ហេតុនេះហើយ គេអាចមើលឃើញគុណវិបត្តិ*"។ *ឯកសារនេះអាចមានតម្លៃខ្លាំងនៅក្នុងករណីតុលាការណាមួយដែលតវ៉ានឹងការបោះឆ្នោតដែលនាំទៅដល់ការចាប់ខ្លួនលោក **ជាម ច័ន្ទនី**...និងបង្ខំឱ្យលោក **សម រង្ស៊ី**...លោក **ជា ប៉ូច** ភៀសខ្លួនចេញពីប្រទេស។*" ចំណែកឯសមាជិកសភាគណបក្សជំទាស់ ឯកឧត្តម **យឹម សុវណ្ណ** បានមានប្រសាសន៍ថា: "*ការបដិសេធកំណត់ហេតុ **មិនមែនជានយោបាយរបស់សភាទេ**។ កំណត់ហេតុនោះតែងតែរក្សាទុកក្នុងបណ្ណាល័យរបស់រដ្ឋសភា ហើយ**លើកនេះជាលើកទីមួយដែលកំណត់ហេតុនេះគេមិនអាចរកបាន**។ សមាជិកសភាគ្រប់គ្នាមានសិទ្ធិមើលកំណត់ហេតុនេះ*"។

ពាក់ព័ន្ធនឹងសមាជិកសភាបីរូបដែលត្រូវបានដកអភ័យឯកសិទ្ធិនោះ អ្នកតំណាងរាស្ត្រសមរង្ស៊ី និង ជា ប៉ូច កំពុងស្នាក់នៅបរទេសនៅឡើយ។ អ្នកតំណាងរាស្ត្រ សម រង្ស៊ី បានបញ្ជាក់ថា នឹងវិលត្រលប់មកកម្ពុជាវិញនៅមុនកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាកិច្ចការព្រំដែន ចំណែកឯកឧត្តម ជាម ច័ន្ទនី នៅតែកំពុងត្រូវបានតុលាការយោធាឃុំខ្លួននៅឡើយក្នុងដំណើរការក្តីក្តាំនេះ។ មេធាវីរបស់អ្នកតំណាងរាស្ត្ររូបនេះ បានជំរុញឱ្យតុលាការកំពូលដំណើរការវិនិច្ឆ័យទោសកូនក្តីរបស់ខ្លួនឱ្យបានឆាប់។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ គណៈកម្មាធិការប្រព្រឹត្តិកម្មបានសំដែងនូវការខកចិត្តតាមរយៈសេចក្តីប្រកាសពត៌មានចុះថ្ងៃទី ២៨ មេសា ២០០៥ ចំពោះចៅក្រម

តុលាការយោធា ដែលមិនទាន់បានឆ្លើយតបចំពោះការស្នើសុំឱ្យគណៈប្រតិភូរបស់គណៈកម្មាធិការខ្លួន ដើម្បីបានចូលសាកសួរសុខទុក្ខឯកឧត្តមអ្នកតំណាងរាស្ត្ររូបនេះ ដោយបានហៅថាទង្វើនេះថា៖ **"ជាការរំលោភលើសិទ្ធិជនជាប់ចោទ"** ហើយក៏បានអំពាវនាវផងដែរដល់ឧត្តមក្រុមប្រឹក្សានៃអង្គការសហប្រជាជាតិ ត្រូវតាមដានមេត្តាពិនិត្យ និងធ្វើអន្តរាគមន៍ចំពោះករណីនេះផង។

នៅក្នុងខែនេះដែរ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** បានដឹកនាំគណៈប្រតិភូសភាកម្ពុជាចូលរួមប្រជុំសមាគមអន្តរសភាលើកទី១១២ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដោយពុំបញ្ចូលប្រតិភូសមាជិកសភាមកពីគណបក្សសមរង្ស៊ីទេ។ ការនេះបានធ្វើឱ្យមានការតវ៉ាពីសមាជិកសភាគណបក្សនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សមាជិកសភាគណបក្សនេះត្រូវបានអញ្ជើញជាភ្ញៀវមិនតំណាងឱ្យសភាកម្ពុជាចូលរួមក្នុងកិច្ចប្រជុំនេះ។

អ្នកតំណាងរាស្ត្រ និងជាប្រធានគណបក្សជំទាស់ សម រង្ស៊ី ប្រកាសថានឹង**មិនទាន់វិលត្រលប់មកប្រទេសវិញទេ** ដោយបារម្ភ**ពីសុវត្ថិភាពផ្ទាល់ខ្លួន** ព្រោះថាដើមបណ្តឹង សម្តេច ហ៊ុន សែន នៅតែព្រលយពាក្យថា **មិនអាចការពារការមិនចាប់ខ្លួនឯកឧត្តម**សមរង្ស៊ីរបស់តុលាការទេ។ ទាក់ទងនឹងបញ្ហានេះដែរ កាលពីថ្ងៃទី ២៨ មេសា ២០០៥ **សភាអ៊ឺរ៉ុបបានអំពាវនាវ**ឱ្យកម្ពុជាបញ្ឈប់ការធ្វើទុក្ខបុកម្នេញប្រឆាំងគណបក្សជំទាស់។ **សភាអ៊ឺរ៉ុប**ជឿជាក់ថា ការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រទាំងបីរូប ដោយរដ្ឋសភាកម្ពុជានេះ **បង្ហាញនូវការរំលោភដ៏ធ្ងន់ធ្ងរបំផុតទៅលើគោលការណ៍ប្រជាធិបតេយ្យ**...។ គណៈកម្មាធិការសិទ្ធិមនុស្សនៃ**សហគមន៍អន្តរសភា** កាលពីថ្ងៃទី ៣-៧ មេសា ២០០៥ ឯទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនជាថ្មីម្តងទៀតបានអំពាវនាវឱ្យមាន**ដំណោះស្រាយសំរាប់វិបត្តិនៅសភាកម្ពុជា**។

ក្រៅពីកិច្ចប្រជុំសភា សកម្មភាពជាលក្ខណៈអន្តរជាតិ និងបញ្ហារបស់សភា អ្នកតំណាងរាស្ត្រមកពីគណបក្សជាប់ឆ្នោតទាំងបីក៏បានធ្វើសកម្មភាពមួយចំនួនតាមរយៈការចុះទៅកាន់មណ្ឌលរបស់ខ្លួន និងមណ្ឌលដទៃទៀតសរុបទាំងអស់ស្មើនឹង **២៨៩** លើក ដែលមានការកើនឡើងបើធៀបទៅនឹងខែកន្លងទៅ។ ការចុះបេសកកម្មទាំងនោះ ភាគច្រើនទាក់ទងនឹងការសាកសួរសុខទុក្ខ ការចែកអំណោយ និងការពង្រឹងផ្ទៃក្នុងគណបក្សផងដែរ។

ខាងក្រោមនេះគឺជារបាយការណ៍សង្ខេប នៃការឃ្លាំមើលសកម្មភាពសភាតំណាងរាស្ត្រ៖

## ១. ការសង្កេតមើលកិច្ចប្រជុំសភាពេញអង្គលើកទី២ នីតិកាលទី៣ :

ក្នុងខែនេះ **ខុមហ្វ្រែល** សង្កេតឃើញមានតែការប្រជុំសភាពេញអង្គពីរលើក ដែលបានអនុម័តសេចក្តីព្រាងច្បាប់ចំនួនមួយក្នុងចំណោមរបៀបវារៈចំនួន ១១ គឺ៖ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ក្រោមអធិបតីភាពសម្តេចក្រុមព្រះដោយមានតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា និងហ្វ៊ុនស៊ិនប៉ិច ចូលរួមសរុបទាំងអស់ចំនួន **៩៣** រូប និងបានជជែកពិភាក្សាច្បាប់ចំនួនមួយគឺសេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មដែលមានសមាជិកសភាចូលរួមសរុបទាំងអស់ចំនួន **៨៧** រូប។

ក្រៅពីកិច្ចប្រជុំសភា គណៈកម្មការជំនាញសភាចំនួន៣ (ទី៣ ទី៥ និងទី៦) បានពិនិត្យ និងពិភាក្សាសេចក្តីព្រាងច្បាប់ទាក់ទិននឹងការគ្រប់គ្រងធនធានទឹក និងកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ស្តីពីការមិនប្រគល់ខ្លួនជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដោយបានអញ្ជើញតំណាងរាជរដ្ឋាភិបាលមកជជែកដេញដោល ដើម្បីសាកសួរ កែសំរួលខ្លឹមសារ ពាក្យពេចន៍ និងអក្ខរាវិរុទ្ធមួយចំនួន។

## **ការឡើងបញ្ចេញមតិរបស់សមាជិក សមាជិការដ្ឋសភា ទាក់ទិននឹងសេចក្តីព្រាងច្បាប់**

នៅក្នុងសម័យប្រជុំពេញអង្គទាំងពីរលើកនេះ សមាជិកសភាដែលមកតែពីរគណបក្សនោះ បានឡើងបញ្ចេញមតិយោបល់ជជែកពិភាក្សាសេចក្តីព្រាងច្បាប់ទាំងពីរដោយបានប្រើថិរៈវេលាសរុបស្មើ ៦១ នាទី ។ នាទីទាំងអស់សំរាប់ការពិភាក្សានេះ ភាគច្រើននិយាយគាំទ្រ និងដាក់សំនួរទៅរាជរដ្ឋាភិបាលមានចំនួននាទីតិចតួចប៉ុណ្ណោះ បាននិយាយចំនុចអវិជ្ជមានចំពោះរាជរដ្ឋាភិបាល ។

ការប្រជុំពេញអង្គទាំងពីរលើកនេះបានពិភាក្សា និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវដែលប្រើរយៈពេលអស់តែមួយព្រឹកប៉ុណ្ណោះ ។ ចំណែកមួយពេលទៀតគឺបានជជែកពិភាក្សាច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានមួយជំពូក ។

នៅក្នុងការជជែកពិភាក្សាសេចក្តីព្រាងច្បាប់នេះ មានសមាជិកសភាទាំងអស់ចំនួន **៩រូប** បានឡើងបញ្ចេញមតិយោបល់ ក្នុងនោះយើងសង្កេតឃើញថា **តំណាងរាស្ត្រមកពីគណបក្សហ៊្វុនស៊ិនប៉ិចមានលក្ខណៈសកម្មជាងគេ**ក្នុងការឡើងបញ្ចេញមតិដែលមានរហូតដល់ ៨ រូប ។ គួរកត់សំគាល់ថា **ខុមហ្វ្រែល** សង្កេតឃើញថាមានតំណាងរាស្ត្រស្រីមកពីគណបក្សហ៊្វុនស៊ិនប៉ិចមណ្ឌលបាត់ដំបង និងព្រៃវែង (លោកជំទាវ **គី លំអង និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិសន្ថា**) បានឡើងបញ្ចេញមតិយោបល់ផងដែរ ។

ប្រធានគណៈកម្មការទីពីរ (សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងពាណិជ្ជកម្ម) និងជាអ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែងឯកឧត្តម **ជាម យៀប** និងជាសមាជិកសភាតែម្នាក់គត់មកពីគណបក្សប្រជាជនកម្ពុជា បានឡើងបញ្ចេញមតិក្នុងសម័យប្រជុំសភា ដែលមានខ្លឹមសារ**គាំទ្រ** (ក្នុងរយៈពេលសរុបប្រមាណ១៣នាទី ស្មើនឹង២១%នៃរយៈពេលសរុប) **ដល់រាជរដ្ឋាភិបាលទាំងស្រុង**ដូចជា: ករណីឯកឧត្តមបានលើកឡើងថា: *"...ការកំទេចបំផ្លាញអាវុធគ្រឿងផ្ទុះរបស់យើងកន្លងមក មានការទទួលស្គាល់ពីសហគមន៍អន្តរជាតិ...នៅពេលមានច្បាប់នេះហើយរាជរដ្ឋាភិបាលនិងមានមូលដ្ឋានកាន់តែច្រើនដើម្បីប្រឆាំង និងការកាន់កាប់អាវុធខុសច្បាប់...* មានការរិះគន់ *មួយចំនួនចំពោះការបំផ្លាញអាវុធរបស់រាជរដ្ឋាភិបាល នេះមកពីអ្នកទាំងនោះមិនបានគិតឱ្យបានដិតដល់ពីគោលបំណងរបស់រាជរដ្ឋា-ភិបាល...ពេលច្បាប់នេះអនុម័តរដ្ឋាភិបាលនឹងពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងអាវុធ"* ។ ឯកឧត្តម **លី ធុជ** តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចមណ្ឌលពោធិសាត់ ក៏បានការពារសកម្មភាពកន្លងមករបស់រាជរដ្ឋាភិបាលដែរ: *"មានអ្នកវិភាគមួយចំនួនបានវាយតំលៃថាសង្គមខ្មែរយើងនឹងមានបញ្ហាអាវុធគ្រឿងផ្ទុះនេះច្រើនបន្ទាប់ពីសង្គ្រាម តែវាផ្ទុយ ព្រោះប្រទេសយើងទទួលបានសុខសុវត្ថិភាព... សុខសុវត្ថិភាពនេះ គឺដោយមានការព្រួតដៃពីសំណាក់រដ្ឋសភា និងរាជរដ្ឋាភិបាលតាំងពីអណត្តិទី១មកម្ល៉េះ ។"*

ទោះបីសមាជិកសភាគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចភាគច្រើនបានបញ្ចេញមតិគាំទ្រ(**ន័យវិជ្ជមាន**) សេចក្តីព្រាងច្បាប់ក៏ដោយ ក៏មានសមាជិកសភាគណបក្សហ៊្វុនស៊ិនប៉ិចមួយចំនួនតិចតួច បានរិះគន់ បន្ទោស និងធ្វើសំណើទៅរាជ-រដ្ឋាភិបាលក្នុងការអនុវត្តន៍ច្បាប់នេះ ជាពិសេសទៅលើការផ្ទុះឃ្លាំងគ្រាប់នៅខេត្តបាត់ដំបងផងដែរ ហើយបានដាក់សំណួរទៅតំណាងរាជរដ្ឋាភិបាលនិងបានលើកពីការព្រួយបារម្ភមួយចំនួនដល់អង្គប្រជុំពិភាក្សាដែលមានខ្លឹមសារ**អវិជ្ជមាន**ដល់រាជរដ្ឋាភិបាល ។ជាក់ស្តែងដូចជា ឯកឧត្តម **លី ធុជ** បានលើកនូវបញ្ហាព្រួយបារម្ភមួយចំនួនដូចជា: *"បញ្ហាដែលសិស្សានុសិស្ស កូនអ្នកមានអំណាចមួយចំនួន បានយកអាវុធទៅប្រើប្រាស់ខុសច្បាប់ក្នុងការគំរាមកំហែងដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលទន់ខ្សោយ និងបញ្ហាមួយទៀតទៅលើអង្គរក្សលោកធំ ឧកញ៉ា និងអ្នកមានលុយដែលជួលអង្គរក្សការពារខ្លួនដោយមានប្រដាប់អាវុធនៅតាមទីសាធារណៈនានា ក៏ដូចជានៅតាមហាងផ្សេងៗដែលវាធ្វើអោយប៉ះពាល់ដល់ភ្ញៀវទេសចរបរទេស និងក្នុងស្រុកមានការភ័យខ្លាច ។"* លោកជំទាវ គី លំអង និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សន្ថា តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចមណ្ឌមបាត់ដំបង និងព្រៃវែង ក៏បានបង្ហាញនូវការចាប់អារម្មណ៏ប្រហាក់ប្រហែលគ្នាផងដែរថា: *"ចំពោះភាពអាណាធិបតេយ្យក្នុងការប្រើប្រាស់អាវុធគ្រឿងផ្ទុះដូចជាការបាញ់សំលាប់ និង*

*ការប្រព្រឹត្តិបទល្មើសនានា ដែលយើងតែងតែឮតាមទំព័រកាសែតដែលធ្វើឱ្យមានការអាក់ដំណើរការអភិវឌ្ឍន៍សង្គម និងធ្វើអោយអ្នកវិនិយោគមិនហ៊ានមកធ្វើការវិយោគ។ បញ្ហាមួយទៀតដែលយើងតែងតែជួបប្រទះដែរ គឺបងតូច បងធំនៅតាមជនបទដែលតែងតែលាក់អាវុធសំរាប់បង្កបទល្មើសផ្សេងៗ។"* និង *"ច្បាប់នេះបានអនុញ្ញាតឱ្យជនស៊ីវិលមួយចំនួនមានសិទ្ធិក្នុងការប្រើប្រាស់អាវុធដូចជាជនមានបុណ្យសក្តិធំៗ ហើយក្នុងរដ្ឋសភាយើងមានរហូតដល់១២៣នាក់ និងក្នុងជួររាជរដ្ឋាភិបាលមួយចំនួនធំទៀត ដែលយើងអាចនឹងឈ្លោះគ្នាដែរ ដែលអាចបង្កអសន្តិសុខក្នុងសង្គមជាតិយើង។"*

ឯកឧត្តម **លី ធុជ** និងលោកជំទាវ គី លំអង បានចោទជាសំនួរមួយចំនួនដល់រាជរដ្ឋាភិបាលមានជាអាទិៈ *"តើរដ្ឋាភិបាលមានវិធានការបែបណាចំពោះការផ្ទុះឃ្លាំងគ្រាប់នៅបាត់ដំបង?* ចំណែកឯអ្នកតំណាងរាស្ត្រ សូ វិចទ័រ មណ្ឌលស្វាយរៀងមកពីគណបក្សហ៊្វុនស៊ិនប៉ិច បានមានសំនួរថាៈ *"ហេតុអ្វីបានជារាជរដ្ឋាភិបាលបំផ្លាញអាវុធជាតិផ្ទុះទាំងនោះ? តាមយោបល់មួយចំនួនបានលើកឡើងថា ទី១ ព្រោះអាវុធទាំងនោះគ្មានគុណភាព និងទី២ ថាយើងត្រូវតែសំអាត ដើម្បីអោយប្រទេសជាតិមានសុខសុវត្ថិភាព។ ចំពោះហេតុផលទាំងពីរខ្ញុំទទួលមិនបាន។ ប្រសិនបើរាជរដ្ឋាភិបាលរក្សាទុកវានោះ យើងនឹងអាចយកទៅប្រើប្រាស់នៅថ្ងៃក្រោយ ហើយប្រសិនបើយើងត្រូវការទិញវិញ វាថ្លៃណាស់រដ្ឋយើងគ្មានលទ្ធភាពទេ ម្យ៉ាងទៀតអាវុធទាំងនោះយើងប្រមូលបានទៅហើយ ឬក៏រដ្ឋាភិបាលគ្មានលទ្ធភាពគ្រប់គ្រងវា?"*

## ២. វិបត្តិខ្វះកូរ៉ុម

វិបត្តិខ្វះកូរ៉ុមប្រជុំបានកំពុងបន្តមាន។ ការពន្យល់មិនច្បាស់លាស់ថា មកពីមានសមាជិកសភាគណបក្សទាំងពីរជាប់បេសកកម្មផ្សេងៗរួមជាមួយកិច្ចការរាជរដ្ឋាភិបាល។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចទាំងពីរនៅតែប៉ុនប៉ងធ្វើ**វិសោធនកម្មរដ្ឋធម្មនុញ្ញ** និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភាដើម្បីបន្ថយចំនួនកូរ៉ុមសំរាប់ប្រជុំសភា ទោះបីជាមានការ**រិះគន់**ពីសំណាក់តំណាងរាស្ត្រគណបក្សជំទាស់ និងសង្គមស៊ីវិលមួយចំនួនថាបានធ្វើឱ្យប៉ះពាល់ដល់រដ្ឋធម្មនុញ្ញក៏ដោយ។គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាក៏បានសំរេច**បង្កើតគណៈកម្មការពិសេសមួយដើម្បីរៀបចំសិក្សាលទ្ធភាពវិសោធនកម្មលើរដ្ឋធម្មនុញ្ញ**។

មានអ្នកផ្តល់យោបល់ថា បើសិនមានការដោះស្រាយបញ្ហាវិបត្តិនយោបាយនៃការបន្តធ្វើពហិការរបស់សមាជិកសភាគណបក្សជំទាស់ **នោះមិនចាំបាច់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបន្ថយកូរ៉ុមសំរាប់ពិភាក្សា** និងអនុម័តក្នុងសម័យប្រជុំពេញអង្គសភានោះទេ។ ចំនួនសមាជិកសភាគណបក្សជំទាស់ ២៤ នាក់ គឺគ្រប់គ្រាន់សំរាប់បន្ថែមឱ្យគ្រប់កូរ៉ុម ហើយក៏បង្ហាញអំពីកិត្យានុកូលភាព និងភាពចាស់ទុំខាងនយោបាយ ដែលមតិចំរុះទាំងគណបក្សជំទាស់ និងគណបក្សកាន់អំនាច។

## ៣. ការសង្កេតមើលបេសកកម្មរបស់អ្នកតំណាងរាស្ត្រចុះនៅកាន់មណ្ឌលនានា

ក្រៅពីកិច្ចប្រជុំសភាពេញអង្គ តំណាងរាស្ត្របានធ្វើសកម្មភាពផ្សេងទៀតរួមមាន ការចុះបេសកកម្មទៅកាន់មណ្ឌល និងការអន្តរាគមន៍ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋមួយចំនួន។ ជាក់ស្តែងនៅក្នុងខែមេសានេះ **ខុមហ្វ្រែល**បានសង្កេតឃើញមានតំណាងរាស្ត្រទាំងអស់ចំនួន**៥៧រូប**ដែលក្នុងនោះ **២៧រូប**មកពីគណបក្សប្រជាជនកម្ពុជា (៣៧%នៃតំណាងរាស្ត្រគណបក្សនេះទាំងអស់) **១៧រូប**មកពីគណបក្សសមរង្ស៊ី(៧១%នៃតំណាងរាស្ត្រនេះទាំងអស់) និង**១៣រូប**មកពីគណបក្សហ៊្វុនស៊ិនប៉ិច (៥០%នៃតំណាងរាស្ត្រគណបក្សនេះទាំងអស់) បានចុះទៅកាន់មណ្ឌលរបស់ខ្លួន និងមណ្ឌលដទៃទៀតសរុបទាំងអស់ស្មើនឹង **២៨៩លើក** ដែលមានការកើនឡើង **២៤%** បើធៀបទៅនឹងខែមីនាដែលមានតែ**២២០លើក**។ អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី បានចុះបេសកកម្មទៅកាន់

មណ្ឌលច្រើនជាងគេគឺស្មើនឹង **១៩០ លើក**, គណបក្សប្រជាជនកម្ពុជាបានចុះ **៧៨ លើក** និងគណបក្សហ៊្វុនស៊ិនប៉ិចបានចុះតែ **២១ លើក** ប៉ុណ្ណោះ។

**ខាងក្រោមនេះគឺជាតារាងសង្ខេបស្តីពីគោលបំណង និងចំនួនបេសកកម្មរបស់អ្នកតំណាងរាស្ត្រ**

| **គោលបំណងនៃការចុះបេសកកម្ម** | **គណបក្សនយោបាយ** | | | **សរុប** |
|---|---|---|---|---|
| | | | | |
| *ការអន្តរាគមន៍ ដោះស្រាយបញ្ហានានា* | ២១ | ០ | ០ | ២១ (៧%) |
| *សាកសួរសុខទុក្ខ ការចែកអំណោយ និងសម្ពោធ* | ១២១ | ៦៣ | ៧ | ១៩១ (៦៧%) |
| *ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស* | ៣១ | ៣ | ៣ | ៣៧ (១៣%) |
| *ការចូលរួមក្នុងវេទិកាសាធារណៈ* | ១៣ | ០ | ៤ | ១៧ (៦%) |
| *ការចុះអមដំណើរថ្នាក់ដឹកនាំ* | ២ | ១២ | ៧ | ២១ (៧%) |
| **សរុប** | **១៩០** | **៧៨** | **២១** | **២៨៩ (១០០%)** |

**ចំពោះការជួយអន្តរាគមន៍ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងមណ្ឌល** តំណាងរាស្ត្រគណបក្សសមរង្ស៊ី បានធ្វើច្រើនជាងគេគឺ**២១ដង** ខុមហ្វ្រែល មិនបានទទួលព័ត៌មានស្តីពីសកម្មភាពនេះពីអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិចទេ។

**ចំពោះការចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋវិញ** អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះច្រើនជាងគេដែរគឺ **១២១ ដង** ហើយ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ **៦៣ ដង** និងគណបក្សហ៊្វុនស៊ិនប៉ិចបានចុះតែ **៧ ដង** ប៉ុណ្ណោះ។ ទាក់ទងទៅនឹង **សកម្មភាពចែកអំណោយវិញ** អ្នកតំណាងរាស្ត្រមកពីគណបក្សទាំងបីនោះ បានឱ្យជាថវិកាដើម្បីស្តារប្រឡាយ អណ្តូង ម៉ាស៊ីនភ្លើងសំរាប់បូមទឹក និងចែកចាយពូជដំណាំដល់ប្រជាកសិករសំរាប់សាបព្រោះ ព្រមទាំងអំណោយផ្សេងៗទៀតនៅក្នុងពិធីសម្ពោធសមិទ្ធិផលនានា ពិធីបញ្ចុះបឋមសីលា កាត់ឫសសីមានៅក្នុងមណ្ឌលមួយចំនួន។

ម្យ៉ាងទៀត ចំពោះ**ការចូលរួមក្នុងវេទិកាសាធារណៈ**ដែលបានរៀបចំដោយ**ខុមហ្វ្រែល** នៅខេត្តសៀមរាប មានការចូលរួមពីសំណាក់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ចំនួន**១រូប** គឺ លោកជំទាវ កែ សុវណ្ណរ័ត្ន។ ចំណែកឯអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងអ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច មិនបានចូលរួមក្នុងវេទិកាទាំងនេះទេ។

ក្នុងចំណោមសកម្មភាពរបស់តំណាងរាស្ត្រទាំង**២៨៩លើក**នេះ មានការចុះក្នុងនាមជាអ្នកតំណាងរាស្ត្រចំនួន**២២៦លើក** ចុះក្នុងនាមគណបក្សនយោបាយមានចំនួន**៣៩លើក**, និងការចុះក្នុងនាមរាជរដ្ឋាភិបាលចំនួន **២៤លើក**។

នៅក្នុងខែនេះផងដែរយើងសង្កេតឃើញថា អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះជួបជាមួយបណ្តាញសកម្មជនរបស់ខ្លួនច្រើនជាងគេ គឺរហូតដល់ **៣១លើក** ក្នុងនោះភាគច្រើនគឺការចុះផ្តល់ពត៌មានស្តីពីការលើកអភ័យឯកសិទ្ធិ និងការឃុំខ្លួនអ្នក-តំណាងរាស្ត្ររបស់គណបក្សខ្លួន។ បន្ទាប់មកគឺគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិចចំនួន **៣** លើកដូចគ្នា។

នៅក្នុងខែមេសា ឆ្នាំ២០០៥ នេះ **ខុមហ្វ្រែល** បានទទួលព័ត៌មានថាមានតំណាងរាស្ត្របានចុះទៅ **១៨** មណ្ឌល។ **មណ្ឌលកណ្តាល**មានអ្នកតំណាងរាស្ត្រចុះច្រើនជាងគេ (**៧៤លើក**) បន្ទាប់មកគឺ **បាត់ដំបង** (៦១លើក)។ ចំណែកឯមណ្ឌលដែលមានតំណាងរាស្ត្រចុះតិចជាងគេ **គឺតែ១លើក** គឺ **ក្រុងកែប**។ គួរបញ្ជាក់ថា នៅក្នុងខែនេះដែរ ឯកឧត្តម **អេង ឆៃអ៊ាង** (តំណាងរាស្ត្រគណបក្សសមរង្ស៊ី មណ្ឌលបាត់ដំបង) បានចុះបេសកកម្មទៅមណ្ឌលរបស់ខ្លួនច្រើនជាងគេ (**៣០លើក**) បន្ទាប់មកគឺឯកឧត្តម **ម៉ៅ សុវណ្ណ** (**២៩លើក**) និងលោកជំទាវ **លី គីមលៀង** និងឯកឧត្តម **ស ខេង** (អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មណ្ឌល

បាត់ដំបង) បានចុះបេសកកម្មទៅក្នុងមណ្ឌលរបស់ខ្លួនបានច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រគណបក្សនេះ ដែលមានចំនួន **៩** និង **៧លើក** និងលោកជំទាវ **គី លំអង** (តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចមណ្ឌលបាត់ដំបង) បានចុះបេសកកម្មច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រគណបក្សនេះ ដែលមានចំនួន **៤លើក** ផងដែរ។

**ការសន្យា និងចំលើយតបរបស់អ្នកតំណាងរាស្ត្រ**

ក្នុងចំណោមបេសកកម្មទាំង **២៨៩លើកនេះ ខុមហ្វ្រែល** សង្កេតឃើញថា យ៉ាងហោចណាស់មានសំណូមពរពីសំណាក់ប្រជាពលរដ្ឋចំពោះអ្នកតំណាងរាស្ត្រចំនួន **៥៥** ករណី (ចំពោះតំណាងរាស្ត្រគណបក្សសមរង្ស៊ី ៥០ ករណី ចំពោះអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា៤ករណី ចំពោះអ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចតែ១ករណីប៉ុណ្ណោះ)ដូចជា: សំណើសុំជួយអន្តរាគមន៍ដោះស្រាយបញ្ហាគ្រោះរាំងស្ងួត បញ្ហាជំលោះដីធ្លី សុំឱ្យអ្នកតំណាងរាស្ត្រចុះជួបប្រជារាស្ត្រឱ្យបានញឹកញាប់។ ឧទាហរណ៍ក្រុមគ្រួសារអ្នកគាំទ្រគណបក្សសម រង្ស៊ី នៅក្នុងខេត្តកំពង់ស្ពឺ ដែលបានស្លាប់ដោយជនមិនស្គាល់មុខសំលាប់ បានសំនូមពរឱ្យឯកឧត្តម នុត រំដួល អ្នកតំណាងរាស្ត្រ ជួយអន្តរាគមន៍ដល់សមត្ថកិច្ចដើម្បីរឹតចាប់ខ្លួនឃាតករមកផ្តន្ទាទោស។ ប្រជាពលរដ្ឋនៅក្នុងខេត្តកោះកុង សូមឱ្យឯកឧត្តម អាយ ខន ជួយជួសជុលទំនប់ទឹកប្រវែង១២គីឡូម៉ែត ពីភូមិប្លោង ដល់ភូមិព្រែក និងពីឃុំស្រែអំបិល ដល់ឃុំបឹងព្រាវ។

រាល់សំណើរបស់ប្រជាពលរដ្ឋត្រូវបានអ្នកតំណាងរាស្ត្រទទួលយក ហើយមានការសន្យារបស់អ្នកតំណាងរាស្ត្រចំនួន **៥ករណី** បានធ្វើឡើង ដែលក្នុងនោះថានឹងជួយដោះស្រាយបញ្ហាជូន ប្រជាពលរដ្ឋតាមសំណូមពរ។ ហើយការឆ្លើយតបចំពោះការសន្យាកាលពីចុះបេសកកម្មលើកមុន១កន្លងមកក៏មានចំនួន **៥**ករណី ដែរ ដែលការឆ្លើយតប នោះប្រជាពលរដ្ឋទទួលបានដូចជាការសន្យាឱ្យអណ្តូង ម៉ាស៊ីនភ្លើង ឬស្ពានប្រឡាយ... ។ល។

**ខុមហ្វ្រែល** សង្កេតឃើញមានការឆ្លើយតបពីសំណាក់អ្នកតំណាងរាស្ត្រ ចំពោះសំណើសំណូមពររបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ឧទាហរណ៍ជាក់ស្តែងដូចជា ករណីអ្នកតំណាងរាស្ត្រ សុក ផេង គណបក្សសមរង្ស៊ីមណ្ឌលកំពង់ធំ ក្នុងឱកាសវេទិកាតំណាងរាស្ត្រ និងរាស្ត្រ រៀបចំដោយ **ខុមហ្វ្រែល** (ថ្ងៃទី ២៩ មីនា ២០០៥ នៅកំពង់ធំ) ប្រជាពលរដ្ឋបានសំណូមពរឱ្យឯកឧត្តមជួយចាត់វិធានការបន្ថយល្បឿនរថយន្ត ទោចក្រយានយន្តបើកបរលើផ្លូវជាតិលេខ ៦ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរ។ នៅថ្ងៃទី ៦ មេសា ២០០៥ នេះ អ្នកតំណាងរាស្ត្ររូបនេះក៏បានសរសេរលិខិតផ្ញើជូនទៅលោកស្នងការនគរបាលខេត្តកំពង់ធំ ឱ្យជួយចាត់វិធានការតាមសំណូមពររបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងយោងតាមសារព័ត៌មានកោះសន្តិភាពផ្សាយថ្ងៃទី ២១ មេសា ២០០៥ បានរាយការណ៍ថា នៅក្នុងកំឡុងពេលបុណ្យចូលឆ្នាំខ្មែរនេះមានគ្រោះថ្នាក់កើតឡើងច្រើនក្នុងបណ្តាខេត្តមួយចំនួន ក្នុងនោះរួមមានកំពង់ធំផងដែរ។

## ៤. លិខិតអន្តរាគមន៍ និងប្រតិកម្មនានារបស់អ្នកតំណាងរាស្ត្រ

នៅក្នុងខែនេះ **ខុមហ្វ្រែល** បានទទួលព័ត៌មានថា យ៉ាងតិចមានតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន១៥រូប បានផ្ញើលិខិតអន្តរាគមន៍/សំនួរចំនួន៧ច្បាប់ ទៅកាន់ស្ថាប័នពាក់ព័ន្ធដូចជា: ស្នងការនគរបាលខេត្តកំពង់ធំ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា រដ្ឋមន្ត្រីក្រសួងពត៌មាន ជាដើម ដោយបានស្នើសុំការចាត់វិធានការចាំបាច់ជាបន្ទាន់ និងដើម្បីជួយស្រាយបំភ្លឺករណីមួយចំនួន និងការទាមទាររបស់ប្រជាពលរដ្ឋ។ ក្នុងនោះដែរ យ៉ាងហោចណាស់មានការឆ្លើយតបចំនួន១ ទៅលិខិតរបស់ឯកឧត្តម **សុន ឆ័យ** ពីសំណាក់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងពត៌មាន ទាក់ទិននឹងការសុំការបំភ្លឺ ពីការផ្សាយព័ត៌មានរបស់ទូរទស្សន៍ជាតិកម្ពុជា។

ពាក់ព័ន្ធទៅនឹងបញ្ហាដែលក្រសួងប្រៃសនីយ៍មានគំរោងបង្កើតក្រុមហ៊ុនទូរស័ព្ទចល័តជាមួយក្រុមហ៊ុនឯកជននោះ ឯកឧត្តម សុន ឆ័យ និងកែវ រ៉េមី មានប្រតិកម្មស្រដៀងគ្នាថា ដំណើរការនេះត្រូវមាន**តម្លាភាព**។